ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
********

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៧៤ អក
ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩
សាលក្រមលេខៈ ០២ (ជជ)
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ប្រាំបួនព្រឹក ដែលមានសមាសភាពចូលរួមជំនុំជម្រះដូចខាងក្រោមៈ

### ចៅក្រមជំនុំជម្រះ

លោក [redacted] ប្រធានសាលាដំបូងខេត្តកណ្តាល

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

-ដើម្បីជំនុំជំម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ៣៧៤ អក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះដូចខាងក្រោមៈ

១.ឈ្មោះ [redacted] សារុន ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ មុខរបរ ជាងជួសជុលម៉ូតូ មានទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] សុភ័ក្រ (រស់) ឪពុកឈ្មោះ [redacted] សារុំ (ស្លាប់) ម្តាយឈ្មោះ [redacted] អន (រស់) ជានីតិជន ទោសពីមុន គ្មាន (ក្រៅឃុំ)។

ជាប់ចោទពីបទៈ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរព កាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិប្រសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

-ជនរងគ្រោះឈ្មោះ [redacted] សិលា ភេទប្រុស អាយុ ៣៩ឆ្នាំ រស់នៅភូមិស្វាយ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិទ្ធ ភេទប្រុស អាយុ ៣៥ឆ្នាំ មុខរបរ បុគ្គលិកក្រុមហ៊ុន មានទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិស្វាយ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល នៅលីវ ឪពុកឈ្មោះ [redacted] វង្ស "ស្លាប់" ម្តាយឈ្មោះ [redacted] យ៉ុន "ស្លាប់"។

ដោយមានមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹង និងជនរងគ្រោះឈ្មោះ [redacted] សិលា។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខៈ ០៦៣ ដកសព ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល ។

-បានឃើញដីកាដំណោះស្រាយលេខៈ ១៩០ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះបន្តលេខៈ ៤២៥ ដកចត/២០ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## **ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ម៉ោង១៩ និង៣០នាទី មានករណីគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើងនៅផ្លូវលំក្រាលគ្រួសក្រហម ស្ថិតនៅភូមិប្រសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល បង្កឡើងដោយម៉ូតូមួយគ្រឿងម៉ាក HONDA CBF ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1GY-9332 បើកបរដោយឈ្មោះ [redacted] សារុន ភេទប្រុស អាយុ២៦ឆ្នាំ ក្នុងទិសដៅបញ្ច្រាសទិសគ្នា មកដល់ចំណុចកើតហេតុខាងលើបានវេចង្កូតចូលចំណែកផ្លូវម្ខាងទៅបុកជាមួយម៉ូតូម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1CU-4642 បើកបរដោយឈ្មោះ [redacted] សិលា ភេទប្រុស អាយុ ៣៩ឆ្នាំ ជនជាតិខ្មែរ និងអ្នករួមដំណើរម្នាក់ទៀតឈ្មោះ [redacted] មករា ភេទប្រុស អាយុ ០៩ឆ្នាំ ជនជាតិខ្មែរ បណ្តាលឱ្យរងរបួសធ្ងន់។

## **នាពេលសវនាការ**

- អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សារុន បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៦ល្ងាច ពេលនោះ ខ្លួនជិះម៉ូតូមួយគ្រឿងម៉ាក HONDA CB ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1GY-9332 ចេញពីកម្មវិធីសែនចិននៅផ្ទះឪក្មេកប្អូនរបស់ខ្លួន គោលបំណងត្រឡប់ទៅផ្ទះវិញ ដោយបើកបរក្នុងទិសដៅពីលិច ទៅកើត មកដល់ផ្លូវគ្រួសក្រហម ស្ថិតនៅភូមិប្រសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ក៏មានម៉ូតូមួយគ្រឿងម៉ាក HONDA DREAM ពណ៌ខ្មៅ មិនចាំស្លាកលេខ ជិះក្នុងទិសដៅពីកើត មកលិច និងមានអ្នករួមដំណើរក្មេងប្រុសម្នាក់ផងដែរ ស្រាប់តែម៉ូតូម៉ាក HONDA DREAM បានជែងរថយន្តមួយគ្រឿងមិនស្គាល់ម៉ាក កំពុងបើកបរយឺតៗក្នុងទិសដៅស្របគ្នាជាមួយម៉ូតូ HONDA DREAM នោះ ហើយក៏បានវេចូលមកចំណែកផ្លូវរបស់ខ្លួន ហើយបានបុកចំពីមុខម៉ូតូខ្លួនពេញមួយទំហឹង បណ្តាលឱ្យខ្លួនសន្លប់ស្មារតី ចំណែកភាគីម្ខាងទៀត ខ្លួនមិនដឹងថា ពួកគាត់ត្រូវរបួសត្រង់ណាងខ្លះនោះទេ។ ខ្លួនត្រូវបានអ្នកនៅជិតកន្លែងកើតហេតុនោះ និងបងប្អូន នាំយកទៅព្យាបាលនៅមន្ទីរពេទ្យនៅស្រុកនោះ ហើយបងប្អូនខ្លួនបានបន្តយកខ្លួនទៅព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃ។ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នេះ បណ្តាលឱ្យខ្លួនរបួសបាក់ធ្មេញលើចំនួន ០៤ និងធ្មេញក្រោមចំនួន ០១ បាក់ចង្ការខាងឆ្វេង និងត្រូវប៉ះពាល់ត្រូវក្បាលធ្ងន់ធ្ងរ បណ្តាលឱ្យមានហូរឈាមតាមត្រចៀក។ ខ្លួនធ្វើការព្យាបាលរបួសតាំងពីថ្ងៃកើតហេតុរហូតមកដល់ពេលនេះ អស់ប្រាក់ប្រហែលជាជាង ២០០០ (ពីរពាន់) ដុល្លារអាមេរិក។ នៅថ្ងៃកើតហេតុនោះ ខ្លួនផឹកស្រាបៀរអស់ប្រហែលពីរកំប៉ុង មិនបណ្តាលឱ្យខ្លួនស្រវឹងនោះទេ។ ខ្លួនបើកបរនៅពេលនោះក្នុងល្បឿន ៤០ គីឡូម៉ែត្រក្នុងមួយម៉ោង មិនបានជិះលឿននោះទេ ចំណែកស្ថានភាពផ្លូវនៅពេលនោះមានគ្រលុកច្រើន ហើយទទឹងផ្លូវប្រហែលជា ០៦ម៉ែត្រ ប៉ុណ្ណោះ មិនអាចបើកបរក្នុងល្បឿនលឿននោះទេ។ ម៉ូតូដែលខ្លួនបើកបរនោះមានកម្លាំងម៉ាស៊ីន ១៥០ ខ្លួនមិនមានប័ណ្ណបើកបរនោះទេ តែម៉ូតូរបស់ខ្លួនមានកញ្ចក់ មានភ្លើងត្រឹមត្រូវ



Scanned with CamScanner

ហើយខ្លួនក៏បានពាក់មួកសុវត្ថិភាពការពារផងដែរ។ ខ្លួនសូមឱ្យតុលាការជួយរកយុត្តិធម៌ឱ្យខ្លួនផង ព្រោះខ្លួនមិនមែនជាអ្នកបង្កគ្រោះថ្នាក់នោះទេ។

- អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិទ្ធ បានឆ្លើយថា នៅថ្ងៃកើតហេតុនោះ ខ្លួនពុំបានឃើញ ហេតុការណ៍ផ្ទាល់នោះទេ។ ខ្លួនត្រូវជាប្អូនថ្លៃរបស់ [redacted] សិលា ដែលបានរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍ ដោយសារឈ្មោះ [redacted] សិលា ត្រូវជាបងថ្លៃរបស់ខ្លួនមានរបួសធ្ងន់មិនអាចចូលរួមមកបំភ្លឺបានទេ ខ្លួនសុំប្តឹងទាមទារសំណងការខូចខាត និងថ្លៃព្យាបាលរបួស ចំនួន ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] សិទ្ធី បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៧ ប្រហែល១០នាទី ខ្លួន និងប្តីឈ្មោះ [redacted] សិលា ព្រមទាំងកូនប្រុសម្នាក់ឈ្មោះ សិលា មករា បានចេញមកពីវត្តស្រោចទឹកនៅវត្តប្រាសាទ ហើយត្រឡប់មកផ្ទះវិញក្នុងទិសដៅពីកើតទៅលិច ដោយខ្លួនបានជិះម៉ូតូ មួយទៀតពីក្រោយប្តីរបស់ខ្លួន ស្រាប់តែមកដល់ចំណុចកើតហេតុស្ថិតនៅភូមិប្រសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល មានម៉ូតូធំមួយគ្រឿងម៉ាក CB ពណ៌ក្រហម មិនស្គាល់ផ្លាកលេខ ជិះក្នុងគោលដៅបញ្ច្រាស់ទិសគ្នាក្នុងល្បឿនលឿនបើកបរដោយបុរសម្នាក់មិនស្គាល់ឈ្មោះ ដែលត្រឡប់មកពីកម្មវិធីសែនចិននៅផ្ទះរបស់បងប្អូនគាត់ បានជិះវេចង្កូតចូលចំណែកផ្លូវប្តីរបស់ខ្លួន ហើយបុកពេញទំហឹងបណ្តាលឱ្យប្តី និងកូនរបស់ខ្លួនរងរបួសធ្ងន់។ នៅថ្ងៃកើតហេតុប្តីរបស់ខ្លួន ពុំបានជិះម៉ូតូជែងរថយន្តណាទេ ប៉ុន្តែមានរថយន្តមួយគ្រឿងចតនៅកៀនខាងស្តាំ ចតនៅចិញ្ចើមផ្លូវហើយប្តីរបស់ខ្លួនជិះកាត់មកផុត ទើបមានម៉ូតូធំម៉ាក CB ពណ៌ក្រហម វេចូលផ្លូវម៉ូតូប្តីរបស់ខ្លួន។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] ចាន់រ៉ា (មន្ត្រីនគរបាលចរាចរណ៍) បានឆ្លើយថា នៅថ្ងៃកើតហេតុ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ មានករណីគ្រោះថ្នាក់ចរាចរណ៍កើតឡើងនៅចំណុចផ្លូវគ្រោះក្រហម ស្ថិតនៅភូមិចេតិយ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល រវាងម៉ូតូម៉ាក DREAM C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1CU-4642 បើកបរដោយឈ្មោះ [redacted] សិលា ដែលបានបើកជែងរថយន្តមួយគ្រឿងទៀត ហើយចូលទៅចំណែកផ្លូវខាងម៉ូតូ CBR ពណ៌ក្រហម ដែលមានស្លាកលេខ 1GY-9332 បើកបរដោយឈ្មោះ អ៊ិក សារុន។ នៅពេលមានគ្រោះថ្នាក់ចរាចរណ៍នៅថ្ងៃខាងលើ ភ្លាមៗនោះ ខ្លួន និងខាងមន្ត្រីជំនាញចរាចរណ៍ពុំបានចុះទៅផ្ទាល់នៅកន្លែងកើតហេតុភ្លាមៗនោះទេ គឺមន្ត្រីប៉ុស្តិ៍ចុះទៅកន្លែងកើតហេតុផ្ទាល់ និងបានកំណត់ចំណុចគោលដៅគ្រោះថ្នាក់ចរាចរណ៍។ លុះនៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង៣០នាទីព្រឹក ខ្លួន និងមានមន្ត្រីជំនាញផ្សេងទៀត ចុះទៅធ្វើការវាស់វែងទៅតាមចំណុចគោលដៅដែលមន្ត្រីប៉ុស្តិ៍បានកំណត់ និងស្តាប់ការបំភ្លឺនៅជុំវិញកន្លែងកើតហេតុ ទើបខាងជំនាញបានសន្និដ្ឋាន បានថាគ្រោះថ្នាក់ចរាចរណ៍នេះជាកំហុសរបស់ខាងម៉ូតូ Dream C125 ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1CU-4642 បើកបរដោយឈ្មោះ ជា សិលា ដែលបានបើកជែងរថយន្តមួយគ្រឿងទៀត ហើយចូលទៅចំណែកផ្លូវខាងម៉ូតូ CBR ពណ៌ក្រហម ដែលមានស្លាកលេខ 1GY-9332 បណ្តាលឱ្យមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង។ ករណីគ្រោះថ្នាក់ចរាចរណ៍នេះ តាមការរាយការណ៍របស់នាយកនគរបាលប៉ុស្តិ៍ឃុំឈ្វាំង គឺបណ្តាលឱ្យភាគីម៉ូតូទាំងសងខាងរងរបួសធ្ងន់។ សាក្សីដែលបានផ្តល់ព័ត៌មានអំពីគ្រោះថ្នាក់ចរាចរណ៍ខាងលើ ពួកគាត់ពុំបានផ្តល់អត្តសញ្ញាណឱ្យមន្ត្រីជំនាញយើងទេ គឺពួកគាត់បានត្រឹមតែផ្តល់ព័ត៌មានប៉ុណ្ណោះ។

- អំណានចម្លើយសាក្សីឈ្មោះ [redacted] វុត្ថា បានឆ្លើយថា ខ្លួនមានតួនាទីជា មន្ត្រីជំនាញចរាចរណ៍។ នៅថ្ងៃកើតហេតុទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោងប្រហែលជា ៥រសៀល ខ្លួនបានទទួលដំណឹងពី



Scanned with CamScanner

លោកនាយប៉ុស្តិ៍ឈ្វាំង ថា មានករណីចរាចរណ៍មួយបានកើតឡើង ស្ថិតនៅភូមិប្រាសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល រវាងម៉ូតូនិងម៉ូតូ។ ពេលនោះ ខ្លួនបញ្ជាឱ្យមន្ត្រីជំនាញរបស់ខ្លួន ចុះទៅកន្លែងកើតហេតុ ទាក់ទងរថយន្តពេទ្យ ដើម្បីសង្គ្រោះជនរងគ្រោះ។ ករណីគ្រោះថ្នាក់ចរាចរណ៍នេះ បង្កឡើងរវាងម៉ូតូម៉ាកសង់ឌ្រីម ពណ៌ខ្មៅ ពាក់ស្លាកលេខ ភ្នំពេញ 1CU-4642 បើកបរដោយឈ្មោះ [redacted] សិលា ភេទប្រុស អាយុ ៣៩ឆ្នាំ បុកជាមួយម៉ូតូធំ០១គ្រឿងទៀតម៉ាក CBR ពណ៌ក្រហម ពាក់ស្លាកលេខ 1GY-9332 បើកបរដោយឈ្មោះ [redacted] សារុន ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ។ សូមបញ្ជាក់ថាក្រោយពីមន្ត្រីជំនាញខ្លួន ចុះទៅវាស់វែងដល់កន្លែងកើតហេតុរួចមក បានធ្វើសេចក្តីសន្និដ្ឋានសរុបរួមថា ករណីគ្រោះថ្នាក់ចរាចរណ៍នេះ ម៉ូតូម៉ាកសង់ឌ្រីម ដែលបើកបរដោយឈ្មោះ [redacted] សិលា បានបើកបរឱ្យបុកគ្នាជាមួយម៉ូតូ CBR ពណ៌ក្រហម ពាក់ស្លាកលេខ 1GY-9332 រងរបួសធ្ងន់ និងស្រាលតែម្តង។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] នាង បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោងជាង ០៦ល្ងាច មានទីតាំងស្ថិតនៅភូមិប្រាសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ពេលនោះ ខ្លួនកំពុងអង្គុយបំបៅដោះកូននៅខាងក្រោមផ្ទះរបស់បងស្រីខ្លួនឈ្មោះ [redacted] នឿន។ ពេលកំពុងបំបៅដោះកូននោះ ខ្លួនបានឃើញម៉ូតូ ០២គ្រឿង បើកបរក្នុងទិសដៅបញ្ច្រាស់គ្នា ដោយម៉ូតូ០១គ្រឿងម៉ាកហុងដា បើកបរដោយមនុស្សប្រុសម្នាក់ មានឌុបកូនប្រុសម្នាក់ តែមិនស្គាល់ឈ្មោះ ហើយក៏មិនដឹងរស់នៅភូមិណានោះទេ និងម៉ូតូមួយគ្រឿងទៀត មិនដឹងម៉ាកអីនោះទេ ដឹងតែម៉ូតូធំ បានបើកបរពីទិសខាងលិចទៅកើត លុះដល់កន្លែងកើតហេតុខាងលើ ខ្លួនបានឃើញម៉ូតូអាសង់ បើកពីក្រោយឡានម៉ាកតាកូម៉ា ពណ៌ឈាមជ្រូក បើកយឺតៗ បន្ទាប់មកម៉ូតូអាសង់នោះ បានបើកវ៉ាឡានតែមិនទាន់ផុតឡានផង ទើបតែបានពាក់កណ្តាលឡាន ក៏បុកគ្នាជាមួយម៉ូតូធំ០១គ្រឿងទៀត បើកបរក្នុងទិសដៅផ្ទុយគ្នា បណ្តាលឱ្យម្ចាស់ម៉ូតូទាំងសងខាង និងកូនប្រុសរបស់អ្នកបើកម៉ូតូអាសង់ សន្លប់ទាំងសងខាង។ ក្រោយពីកើតហេតុ ខ្លួន រួមនឹងអ្នកជិតខាង បាននាំគ្នាយករ៉ឺម៉កដឹកទៅមន្ទីរពេទ្យឯកជននៅភូមិត្រពាំងស្មោ ហើយពេទ្យមិនហ៊ានទទួលព្យាបាល បន្ទាប់មកបងប្អូនសាច់ញាតិភាគីទាំងសងខាងក៏មកដល់ និងបញ្ជូនបន្តទៅពេទ្យនៅភ្នំពេញ។ ខ្លួនមិនបានឃើញថា ភាគីណាជាអ្នកបង្កគ្រោះថ្នាក់ចរាចរណ៍នោះទេ ខ្លួនគ្រាន់តែឃើញបុកគ្នាតែប៉ុណ្ណោះ។ ពេលដែលបុកគ្នានោះ ភាគីខាងម៉ូតូអាសង់ បានដួលទៅខាងក្រោមឡានតាកូម៉ា ។ ខ្លួនមិនបានដឹងថា ភាគីណាបើកបរក្នុងល្បឿនប៉ុន្មាននោះទេ គ្រាន់តែដឹងថាបើកបរយឺតៗតែប៉ុណ្ណោះ ពីព្រោះផ្លូវនោះជាផ្លូវលំដែលមានទំហំប្រហែល០៣ម៉ែត្រ ហើយស្ថានភាពផ្លូវវាមានគ្រលុកច្រើន។

-មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនរងគ្រោះឈ្មោះ [redacted] សិលា បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនសុំរក្សាសេចក្តីសន្និដ្ឋានដូចមាននៅក្នុងសេចក្តីសន្និដ្ឋានការពារក្តី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ ដែលបានដាក់ចូលរដ្ឋបាលរួចហើយ ទុកជាបានការទាំងស្រុង និងសូមធ្វើការបញ្ជាក់បន្ថែមដូចតទៅ តាមមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក បានចែងអំពីបទ "បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ" ត្រូវបានច្បាប់បញ្ញត្តិដូចតទៅ៖ ជនណាបើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចដែលបទប្បញ្ញត្តិស្តីពីចរាចរណ៍ផ្លូវគោកតម្រូវ បណ្តាលឱ្យរបួសដល់អ្នកដទៃ ហើយបណ្តាលឱ្យអ្នករងគ្រោះអសមត្ថភាពធ្វើការងារក្នុងរយៈពេលស្មើ ឬលើសពី៨ថ្ងៃ គិតចាប់ពីថ្ងៃកើតហេតុត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ២០០០០០០ (ពីរលាន) រៀល ទៅ ១០ ០០០០០០ (ដប់លាន) រៀល និងអាចត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុង



Scanned with CamScanner

មាត្រា ៥៣ (ប្រភេទនៃទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ។ យោងតាមអង្គហេតុខាងលើ ជនជាប់ចោទឈ្មោះ [redacted] សារុន បានបើកបរស្ថិតនៅក្នុងស្ថានភាពស្រវឹង ដោយខ្លួនបានផឹកស្រាបៀរនៅកម្មវិធីសែនចិន នៅផ្ទះប្អូនថ្លៃរបស់ខ្លួន។ ការទទួលទានគ្រឿងស្រវឹងនេះ គួបផ្សំជាមួយការបើកបរដោយធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន និងការបើកបរនៅក្នុងល្បឿនលឿន ធ្វើឱ្យជននេះបាត់បង់ភាពម្ចាស់ការទៅលើយានជំនិះរបស់ខ្លួន ហើយជ្រុលចង្កូតទៅបុកម៉ូតូរបស់ជនរងគ្រោះឈ្មោះ [redacted] សិលា បណ្តាលឱ្យឈ្មោះ [redacted] សិលា (ឪពុក) និង សិលា មករា (កូន) រងរបួសធ្ងន់ត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យជាច្រើនថ្ងៃ។ អំពើរបស់ឈ្មោះ [redacted] សារុន ត្រូវបានច្បាប់បញ្ញត្តិថាជាបទល្មើស បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ និងត្រូវផ្តន្ទាទោសតាមរយៈ មាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ យោងទៅតាមការបកស្រាយខាងលើអាចបញ្ជាក់បានថា លោក [redacted] សារុន ពិតជាបានប្រព្រឹត្តបទល្មើស បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យមានរបួសអ្នកដទៃ ដែលប្រព្រឹត្តនៅផ្លូវលំក្រាលគ្រួសក្រហម ភូមិប្រាសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល តាមការចោទប្រកាន់ ពិតប្រាកដមែន។ យោងតាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុន នៅដំណាក់កាលចៅក្រមស៊ើបសួរ បានឆ្លើយសារភាពថា ខ្លួនបានផឹកគ្រឿងស្រវឹង ហើយបានសម្រេចចិត្តបើកបរចេញពីទីតាំងនៃផ្ទះដែលមានកម្មវិធីសែនទៅកាន់ផ្ទះរបស់ខ្លួន។ គួរពិចារណាថាឈ្មោះនេះ គឺជានីតិជន និងត្រូវបានច្បាប់ចាត់ទុកថាបានដឹងច្បាស់ អំពីព្យសនកម្មដែលអាចកើតឡើងចេញពីអំពីរបស់ខ្លួន ប្រសិនបើខ្លួនធ្វើការបើកបរដោយស្ថិតនៅក្រោមស្ថានភាពស្រវឹង ប៉ុន្តែឈ្មោះនេះនៅតែសម្រេចចិត្តបើកបរទៅកាន់ផ្ទះរបស់ខ្លួន។ ក្រោយពីបានទទួលទានគ្រឿងស្រវឹងគួបផ្សំជាមួយការបើកបរដោយធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន និងការបើកបរនៅក្នុងល្បឿនលឿន ធ្វើឱ្យជននេះបាត់បង់ភាពម្ចាស់ការទៅលើយានជំនិះរបស់ខ្លួន ហើយជ្រុលចង្កូតទៅបុកម៉ូតូរបស់ជនរងគ្រោះ បណ្តាលឱ្យជនរងគ្រោះទទួលរងរបួសធ្ងន់។ លើសពីនេះទៅទៀត អំពើល្មើសច្បាប់របស់ជនជាប់ចោទ ឈ្មោះ [redacted] សារុន បានបង្កឱ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរមកលើរូបរាងកាយរបស់ជនរងគ្រោះទាំងពីររូប បង្កើតឱ្យមានចំណាយលើថ្លៃព្យាបាលរបួសជាច្រើន និងធ្វើឱ្យលោក [redacted] សិលា ដែលជាមេគ្រួសារ បាត់បង់សមត្ថភាពក្នុងការរកចំណូលដើម្បីទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ក្រុមគ្រួសារ និងដើម្បីព្យាបាលខ្លួនឯងផ្ទាល់ និងកូនរបស់ខ្លួនដែលមានរបួសធ្ងន់ មួយរយៈពេលធំ។ ហេតុដូច្នេះ ខ្លួនសុំឱ្យលោកចៅក្រម មេត្តាសម្រេចផ្តន្ទាទោសឈ្មោះ [redacted] សារុន ទៅតាមកំណត់ច្បាប់ និងបង្គាប់ឱ្យឈ្មោះនេះសងការខូចខាត និងជម្ងឺចិត្តទៅឱ្យជនរងគ្រោះឈ្មោះ [redacted] សិលា ចំនួន ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖ ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី នាពេលសវនាការ ឃើញ ជនជាប់ចោទឈ្មោះ [redacted] សារុន ពិតជាបានប្រព្រឹត្តអំពើ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន មិនគោរពកាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ ប្រព្រឹត្តនៅភូមិប្រសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។ ហេតុដូច្នេះ តំណាងអយ្យការ នៅតែរក្សាបទចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរដដែល និងស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមផ្លូវច្បាប់។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី



Scanned with CamScanner

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការប្តឹងសុំ

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តកណ្តាល

## យល់ឃើញថា

-ជនជាប់ចោទឈ្មោះ [redacted] សារុន ជានីតិជន មានស្មារតីគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវនូវអំពើដែលខ្លួនប្រព្រឹត្ត ហើយក៏ពុំមានសញ្ញាណណាមួយ ដែលអាចបញ្ជាក់ថា ជនជាប់ចោទមានបញ្ហាវិបល្លាសស្មារតីឡើយ ។

-អំពើរបស់ជនជាប់ចោទ គឺជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ និងសន្តិសុខសណ្តាប់ធ្នាប់សង្គម ដែលច្បាប់បានហាមឃាត់ ហើយបានបញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុន បានឆ្លើយថា កាលពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៦ល្ងាច ពេលនោះ ខ្លួនជិះម៉ូតូមួយគ្រឿងម៉ាក HONDA CB ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1GY-9332 ចេញពីកម្មវិធីសែនចិននៅផ្ទះឪក្មេកប្អូនរបស់ខ្លួន គោលបំណងត្រឡប់ទៅផ្ទះវិញ ដោយបើកបរក្នុងទិសដៅពីលិច ទៅកើត មកដល់ផ្លូវគ្រួសក្រហម ស្ថិតនៅភូមិប្រសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ក៏មានម៉ូតូមួយគ្រឿងម៉ាក HONDA DREAM ពណ៌ខ្មៅ មិនចាំស្លាកលេខ ជិះក្នុងទិសដៅពីកើត មកលិច និងមានអ្នករួមដំណើរក្មេងប្រុសម្នាក់ផងដែរ ស្រាប់តែម៉ូតូម៉ាក HONDA DREAM បានជែងរថយន្តមួយគ្រឿងមិនស្គាល់ម៉ាក កំពុងបើកបរយឺតៗក្នុងទិសដៅស្របគ្នាជាមួយម៉ូតូ HONDA DREAM នោះ ហើយក៏បានវេចូលមកចំណែកផ្លូវរបស់ខ្លួន ហើយបានបុកចំពីមុខម៉ូតូខ្លួនពេញមួយទំហឹង បណ្តាលឱ្យខ្លួនសន្លប់ស្មារតី ចំណែកភាគីម្ខាងទៀត ខ្លួនមិនដឹងថា ពួកគាត់ត្រូវរបួសត្រង់ណាងខ្លះនោះទេ។ ខ្លួនត្រូវបានអ្នកនៅជិតកន្លែងកើតហេតុនោះ និងបងប្អូន នាំយកទៅព្យាបាលនៅមន្ទីរពេទ្យនៅស្រុកនោះ ហើយបងប្អូនខ្លួនបានបន្តយកខ្លួនទៅព្យាបាលនៅមន្ទីរពេទ្យលោកសង្ឃ។ ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍នេះ បណ្តាលឱ្យខ្លួនរបួសបាក់ធ្មេញលើចំនួន ០៤ និងធ្មេញក្រោមចំនួន ០១ បាក់ចង្ការខាងឆ្វេង និងត្រូវប៉ះពាល់ត្រូវក្បាលធ្ងន់ធ្ងរ បណ្តាលឱ្យមានហូរឈាមតាមត្រចៀក។ ខ្លួនធ្វើការព្យាបាលរបួសតាំងពីថ្ងៃកើតហេតុរហូតមកដល់ពេលនេះ អស់ប្រាក់ប្រហែលជាជាង ២០០០ (ពីរពាន់) ដុល្លារអាមេរិក។ នៅថ្ងៃកើតហេតុនោះ ខ្លួនផឹកស្រាបៀរអស់ប្រហែលពីរកំប៉ុង មិនបណ្តាលឱ្យខ្លួនស្រវឹងនោះទេ។ ខ្លួនបើកបរនៅពេលនោះក្នុងល្បឿន ៤០ គីឡូម៉ែត្រក្នុងមួយម៉ោង មិនបានជិះលឿននោះទេ ចំណែកស្ថានភាពផ្លូវនៅពេលនោះមានគ្រលុកច្រើន ហើយទទឹងផ្លូវប្រហែលជា ០៦ម៉ែត្រ ប៉ុណ្ណោះ មិនអាចបើកបរក្នុងល្បឿនលឿននោះទេ។ ម៉ូតូដែលខ្លួនបើកបរនោះមានកម្លាំងម៉ាស៊ីន ១៥០ ខ្លួនមិនមានប័ណ្ណបើកបរនោះទេ តែម៉ូតូរបស់ខ្លួនមានកញ្ចក់ មានភ្លើងត្រឹមត្រូវ ហើយខ្លួនក៏បានពាក់មួកសុវត្ថិភាពការពារផងដែរ។

-តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិទ្ធ បានឆ្លើយថា នៅថ្ងៃកើតហេតុនោះ ខ្លួនបានឃើញហេតុការណ៍ដោយផ្ទាល់ទេ ហើយបងថ្លៃខ្លួនឈ្មោះ [redacted] សិលា និងក្មួយប្រុសខ្លួនឈ្មោះ សិលា មករា បានរងរបួសជាទម្ងន់ក្នុងករណីគ្រោះថ្នាក់ចរាចរណ៍។

-តាមចម្លើយសាក្សីឈ្មោះ [redacted] សិទ្ធី បានឆ្លើយថា កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ០៧ ប្រហែល១០នាទី ខ្លួន និងប្តីឈ្មោះ [redacted] សិលា ព្រមទាំងកូនប្រុសម្នាក់ឈ្មោះ សិលា មករា បានចេញមកពីវត្តស្រោចទឹកនៅវត្តប្រាសាទ ហើយត្រឡប់មកផ្ទះវិញក្នុងទិសដៅពីកើតទៅលិច ដោយខ្លួនបានជិះម៉ូតូ មួយទៀតពីក្រោយប្តីរបស់ខ្លួន ស្រាប់តែមកដល់ចំណុចកើតហេតុស្ថិតនៅភូមិប្រសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល មានម៉ូតូធំមួយគ្រឿងម៉ាក CB ពណ៌ក្រហម មិនស្គាល់ផ្លាកលេខ ជិះក្នុងគោលដៅបញ្ច្រាស់ទិសគ្នាក្នុងល្បឿនលឿនបើកបរដោយបុរសម្នាក់មិនស្គាល់ឈ្មោះ ដែលត្រឡប់មកពីកម្មវិធីសែនចិននៅផ្ទះរបស់បងប្អូនគាត់ បានជិះវេចង្កូតចូលចំណែកផ្លូវប្តីរបស់ខ្លួន ហើយបុកពេញទំហឹងបណ្តាលឱ្យប្តី និងកូនរបស់ខ្លួនរងរបួសធ្ងន់។ នៅថ្ងៃកើតហេតុប្តីរបស់ខ្លួន ពុំបានជិះម៉ូតូជែងរថយន្តណាទេ ប៉ុន្តែមានរថយន្តមួយគ្រឿងចតនៅកៀនខាងស្តាំ ចតនៅចិញ្ចើមផ្លូវហើយប្តីរបស់ខ្លួនជិះកាត់មកផុត ទើបមានម៉ូតូធំម៉ាក CB ពណ៌ក្រហម វេចូលផ្លូវម៉ូតូប្តីរបស់ខ្លួន។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] សារុន, ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី និងរបាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ ធៀបនឹងឯកសារគតិយុត្តិផ្សេងៗ ឃើញថា មានភស្តុតាង និងមានធាតុផ្សំគ្រប់គ្រាន់ បញ្ជាក់អោយឃើញថា ជនជាប់ចោទឈ្មោះ [redacted] សារុន ពិតជាបានប្រព្រឹត្តនូវអំពើ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច បណ្តាលឱ្យមានរបួសដល់អ្នកដទៃ** កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ នៅភូមិប្រាសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល ប្រាកដមែន ដោយជនជាប់ចោទ ស្ថិតនៅក្នុងស្ថានភាពស្រវឹង និងពេលមានឧបសគ្គនៅខាងមុខបាត់ភាពម្ចាស់ការ ហើយជ្រុលចង្កូតទៅបុកម៉ូតូម្ខាងទៀតក្នុងទិសដៅបញ្ច្រាសទិសគ្នា បណ្តាលឱ្យជនរងគ្រោះរងរបួសធ្ងន់ ទាំងពីរនាក់ឪពុក និងកូន ដែលអំពើនេះ ច្បាប់បញ្ញត្តិជាបទល្មើសព្រហ្មទណ្ឌ បទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យមានរបួសដល់អ្នកដទៃ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ មានអំណះអំណាងសមហេតុផល អាចឲ្យតុលាការយកមកពិនិត្យ និងពិចារណាបាន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ ២៦ឆ្នាំ ពីបទៈ **បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ច បណ្តាលឱ្យមានរបួសដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិប្រាសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៨៣** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

-វត្ថុតាងមានដូចជាៈ ម៉ូតូម៉ាក **HONDA CBR** ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ **1GY-9332** និងម៉ូតូម៉ាក **HONDA DREAM C125**ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ **1CU-4642** គប្បីសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិទ្ធ ទាមទារសំណងការខូចខាត និងថ្លៃព្យាបាលរបួសបងថ្លៃរបស់ខ្លួនឈ្មោះ [redacted] សិលា ចំនួន ៣០០០០ (បីម៉ឺន) ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] សារុន។ ហេតុដូច្នេះ តុលាការនឹងពិចារណាពីសំណងរដ្ឋប្បវេណីទៅតាមព្យសនកម្មជាក់ស្តែង។

**<u>ហេតុដូច្នេះសម្រេច</u>**

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេលចំនួន ០១ (មួយ) ឆ្នាំ ។



Scanned with CamScanner

ពីបទ បើកបរដោយធ្វេសប្រហែស ខ្ជីខ្ជា មិនប្រុងប្រយ័ត្ន ឬមិនគោរពកាតព្វកិច្ចបណ្តាលឱ្យរបួសអ្នកដទៃ ប្រព្រឹត្តនៅភូមិប្រាសាទ ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល កាលពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨៣ នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted] សារុន ភេទប្រុស អាយុ ២៦ឆ្នាំ សងសំណងការខូចខាត និងថ្លៃព្យាបាលរបួស ដល់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិទ្ធ ជាប្រាក់ចំនួន ២០០០០ (ពីរម៉ឺន) ដុល្លារអាមេរិក។ ការទាមទារលើសពីនេះលើកចោល។

៣-ប្រគល់ ម៉ូតូម៉ាក HONDA CBR ពណ៌ក្រហម ពាក់ផ្លាកលេខ ភ្នំពេញ 1GY-9332 និងម៉ូតូម៉ាក HONDA DREAM C125ពណ៌ខ្មៅ ពាក់ផ្លាកលេខ ភ្នំពេញ 1CU-4642 ឱ្យម្ចាស់ដើមវិញ។

៤-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សារុន និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សារិទ្ធ និងចំពោះមុខមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា
[redacted]

---

(បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម)
ថ្ងៃអង្គារ ៧កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
កណ្តាល, ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០
**ក្រឡាបញ្ជី**
[redacted]

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]